# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្តព្រះវិហារ**

លេខៈ ៦៣៧ ១៦ -សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតលេខាធិការដ្ឋាននៃគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១

## អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ
## និងជាប្រធានគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៤/៦៥០ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្តព្រះវិហារ អាណត្តិទី២ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៦/៧៦០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៦ ស្តីពីការតែងតាំងអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៦/០៤៣ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ស្តីពីការបង្កើតគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយ ផលិតផលមួយ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៣/១០៥៩ ស្តីពីការផ្ទេរគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយ ផលិតផលមួយ ដោយធ្វើសមាហរណកម្មការងារជំរុញចលនាភូមិមួយ ផលិតផលមួយ ឲ្យស្ថិតនៅក្រោមការទទួលខុសត្រូវនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈ អភិបាលស្រុក ។
- យោងប្រកាសលេខ ៤២៧៤ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាក្រុង ការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាស្រុក និងការកំណត់តួនាទីភារកិច្ចរបៀបរបបការងារនៃការិយាល័យទាំងនោះ ។
- បានឃើញប្រកាសអន្តរក្រសួងលេខ ៣២៤ ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- យោងលិខិតលេខ ០២៩ ភ.១ ផ.១ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៥ របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ។

- យោងសេចក្តីសម្រេចលេខ ០៥៩ សសរ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ របស់រដ្ឋបាលខេត្តព្រះវិហារ ស្តីពីការបង្កើតគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ ។

**សម្រេច:**

**ប្រការ១** ៖ ត្រូវបានបង្កើត " **លេខាធិការដ្ឋាននៃគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១** " ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ០១- លោក | **យ៉ុង គីមហឿង** | នាយករងរដ្ឋបាលសាលាខេត្ត | ប្រធាន |
| ០២- លោក | **ហេង សោភ័ណ្ឌ** | អនុប្រធានមន្ទីរពាណិជ្ជកម្ម | អនុប្រធាន |
| ០៣- លោក | **យូ សុខា** | អនុប្រធានមន្ទីរទេសចរណ៍ | សមាជិក |
| ០៤- លោក | **អ៊ុំ សុប្ញរិទ្ធ** | អនុប្រធានមន្ទីរបរិស្ថាន | សមាជិក |
| ០៥- លោក | **ស្រ៊ុន បូរិទ្ធ** | អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ០៦- លោក | **គល់ វីរៈ** | អនុប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ០៧- លោក | **មាស សុគន្ធ** | អនុប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ០៨- នាយករដ្ឋបាលសាលាក្រុង-ស្រុក | | | សមាជិក |

**ប្រការ២** ៖ លេខាធិការដ្ឋាននៃគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ មានតួនាទី ភារកិច្ច ដូចខាងក្រោម ៖

- ជាសេនាធិការឲ្យគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ ។
- រៀបចំទីកន្លែងប្រជុំរបស់គណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ ។
- រៀបចំរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ របស់គណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ ។
- រៀបចំកិច្ចការផ្សេងៗទៀត តាមការណែនាំរបស់គណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ ។

**ប្រការ៣** ៖ នាយករដ្ឋបាលសាលាខេត្ត នាយកទីចាត់ការទាំង០៥ និងប្រធានអង្គភាពលទ្ធកម្មចំណុះរចនាសម្ព័ន្ធសាលាខេត្ត ប្រធានមន្ទីរ-អង្គភាពពាក់ព័ន្ធ អភិបាលក្រុង-ស្រុក និងអស់លោក លោកស្រីដែលមានឈ្មោះក្នុងប្រការ១ខាងលើ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/.

ធ្វើនៅខេត្តព្រះវិហារ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០១៦

**អភិបាលខេត្ត**

**និងជាប្រធាន គ.ខ.ភ១ ផ១**

អ៊ុំ ចាន់ជា

**កន្លែងទទួល:**

-អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ ផលិតផល១
-ក្រុមប្រឹក្សាខេត្ត
-គណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១
"ដើម្បីជូនជ្រាប"
-ដូចក្នុងប្រការ៣
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ